# បងអប់រំខ្ញី

## ស្តីអំពីៈ ដើមឈើធំ រលំឮខ្លាំង

គតិសាស្ត្រ "បុគ្គលធ្លាប់ជាទីសក្ការត្រូវគេគោរព បូជា ឬបុគ្គលដែលមានបុណ្យយសតំណែងខ្ពស់ មិនត្រូវឲ្យមានពិរុទ្ធភាពទេ, កាលណាមានពិរុទ្ធភាពហើយកេរ្តិ៍ឈ្មោះអាក្រក់ត្រូវសាយភាយលាន់ឮឆ្ងាយក្តាត់"

នេះជាព្រឹត្តិការណ៍ពិតក្នុងសង្គមខ្មែរ នៃលោក និងកូនសេក្ខនិងការប្រតិកម្មរបស់រដ្ឋាភិបាល ។ ពាក្យស្លោកខ្មែរថា "**ដើមឈើធំ រលំឮខ្លាំង**" សម្រាប់ហៅអ្នកដែលត្រូវគោរព ឬអ្នកដែលមានបុណ្យសក្តិធំ ប្រោះធ្លោយខ្លួនក្នុងទោសអ្វីមួយហើយលេចឮឈ្មោះអាក្រក់ខ្លាំង ។ នៅក្នុងសង្គមខ្មែរ ព្រះសង្ឃក្នុងព្រះពុទ្ធសាសនា គឺជាបុគ្គលជាទីគោរពពេញនិយមសម្បើមដែរនៃប្រជាពលរដ្ឋខ្មែរស្ទើរតែទូទៅ ។ ហ៊ាន

តែព្រះសង្ឃអង្គណា ប្រព្រឹត្តខុសឆ្គាំឆ្គងទំនាស់នឹងធម៌វិន័យរបស់ព្រះពុទ្ធត្រង់ខណាមួយនោះ, បណ្ឌិតបញ្ញវន្តអ្នកឆ្លាតគេមិនហៅ "**ព្រះសង្ឃអាក្រក់ឬព្រះសង្ឃប្រព្រឹត្តកំហុស**"ទេ, គឺគេហៅថា "**លោកម្ចាស់រូបនេះរូបនោះអាក្រក់ ប្រព្រឹត្តកំហុស**" ។ ដោយឡែកអក័ព្វតែប្រជាពលរដ្ឋក្នុងសង្គមខ្មែរស្ទើរតែគ្រប់ស្រទាប់វណ្ណៈរាប់ទាំងអ្នករដ្ឋការផង ប្រកាសខ្លួនថាជាពុទ្ធសាសនិក នៅតែមិនយល់វិនិច្ឆ័យខុសទំនងរវាងពាក្យថា "**សង្ឃ**" និងពាក្យថា "**បុគ្គល**" ឲ្យដាច់ស្រេចច្បាស់លាស់និងត្រឹមត្រូវទៀត ។ ពួកគេឲ្យតែឃើញអ្នកបួសអង្គណាមួយប្រព្រឹត្តខុសនឹងវិន័យក្រឹត្យ ក៏នាំគ្នាថ្កោលទោសជាទម្ងន់ទាំងងងឹតងងល់ ហើយមានអ្នកខ្លះទៀតតាំងខ្លួនឯងដូចជាមេធាវីចំណាននៃព្រះពុទ្ធជាម្ចាស់អ៊ីចឹងខណៈដែលមានកន្ទែងខ្វះវិន័យនោះ មានទម្ងន់ទោសមិនស្មើនឹងចោរលួចកញ្ចក់ម៉ូតូមួយផង មិនស្មើនឹងក្មេងទំនើងវាយតប់គ្នាផង ។ ករណីអ្នកបួសអង្គណាមួយ ប្រព្រឹត្តល្មើសនូវពុទ្ធប្បញ្ញត្តិ ទោះបីលហុទោសទោះបីគរុទោសសូម្បីបន្តិចបន្តួច, ពួកគេហាក់ដូចជាត្រចៀកវៃ ភ្នែកភ្លឺ បបូរមាត់មាន

សេរីភាពពេញលេញណាស់ អាចឮអាចមើលឃើញអាចនិយាយប្រកាសផ្សព្វផ្សាយពត៌មានដ៏ល្បីរន្ទឺនេះ លឿនរហ័សទាន់ចិត្តស្មើរតែពេញមួយពិភពលោក, នេះប្រសិនបើឋានព្រះឥន្ទ្រមានបណ្ដាញប្រព័ន្ធ Internet សម្រាប់ទំនាក់ទំនងដោយ Direct ជាមួយមនុស្សលោកទៀត ពត៌មាននេះនឹងហោះលោតចូលក្នុងគេហទំព័រដោយឯងៗ មិនចាំបាច់ព្រះឥន្ទ្រលំបាកបើកព្រះនេត្រទិព្វទតមើលឡើយ ។ តែបើករណីរឿងចោរលួចប្លន់ រឿងក្មេងទំនើង រឿងព្រំដែនរឿងទឹកដី រឿងឧក្រិដ្ឋកម្មបំផ្លាញធម្មជាតិ រឿងដីសម្បទានខុសច្បាប់ រឿងអំពើពុករលួយ រឿងយុវជនអត់ការងារធ្វើរឿងគម្លាតរវាងអ្នកមាននិងអ្នកក្រ និងរឿងជាច្រើនទៀតដែលទាក់ទងនឹងវាសនាប្រទេស វាសនាកូនចៅរបស់ខ្លួនយ៉ាងណានោះ ហើយជារឿងដែលត្រូវនាំគ្នាដឹងឮពិនិត្យមើល និយាយជជែកគ្នាជាទីបំផុតនុ៎ះ មិនឃើញពួកគេត្រចៀកវៃ ភ្នែកទិព្វ សម្ដីបបូរមាត់មានសេរីភាព ហាស្រែកប្រកាសផ្សព្វផ្សាយប្រាប់មហាជន និងពិភពលោកទូទៅឲ្យបានដឹងសោះ បែរជានាំគ្នាបិទពត៌មានស្ងាត់ឈឹង ស្ងួម្បី

តែព្រះឥន្ទ្របើកព្រះនេត្រទិព្វឡើងផ្សាស្រវាំងព្រះនេត្រអស់ទៅហើយ ក៏នៅតែទតពុំឃើញនូវអំពើអាក្រក់ពួកគេទៀត រហូតដល់ទៅចាត់**ចតុលោកបាលទាំង ៤** ឲ្យតាមដានត្រួតពិនិត្យនូវរាល់សកម្មភាពមនុស្សលោក ក៏នៅតែរកពិរុទ្ធភាពពួកគេមិនឃើញដដែល ។

នេះគ្រាន់តែជាបទវិភាគពិចារណា ដើម្បីឲ្យមានសមភាពទៅនឹងប្រសាសន៍ លោកនាយករដ្ឋមន្ត្រីកម្ពុជា គឺ **សម្តេច ហ៊ុន សែន** ដែលថ្លែងថា **"ព្រះសង្ឃ នៅខេត្តបន្ទាយមានជ័យ ដែលធ្វើទារុណកម្មលើកូនក្មេងអាយុ៩ឆ្នាំ មិនអាចអត់ឱនបានទេ"**។ សម្តេចជាបុគ្គលធ្លាប់រស់នៅអាស្រ័យក្នុងវត្តជាមួយព្រះសង្ឃ ហើយខិតខំព្យាយាមប្រវេប្រវាជាទីបំផុត រហូតបានក្លាយជានាយករដ្ឋមន្ត្រី ត្រូវបានប្រជាជនអ្នកគាំទ្រចាត់ទុក និងសរសើរស្ទើរសឹកបបូរមាត់ថា **"ជាវីរកុលបុត្រសម្បូណ៌ប្រាជ្ញាគតិបណ្ឌិតមានថ្វីមាត់ល្អ"**, បើដូច្នោះ ឃើញថាសម្តេចអស្ចារ្យពេកណាស់ តែពុំគួរប្រើភាសាកំប៉ិកំប៉ុកបែបនេះច្រឡំទេ ខ្ញុំសូមជួយកែតម្រូវប្រសាសន៍និងវិនិច្ឆ័យពន្យល់សម្តេចខ្លះៗទៅចុះ ក្រែង

កាលសម្តេចនៅវត្តក្នុងសម័យបដិវត្តន៍រវល់រំដោះជាតិ ពុំបានឈ្វេងយល់នូវគោលវិន័យព្រះពុទ្ធសាសនាផងឡើយ ។

សូមសម្តេចមេត្តាជ្រាប ! ពាក្យថា "**ព្រះសង្ឃ**" និងពាក្យថា "**បុគ្គល**" ពុំដូចគ្នាទេ, ពាក្យថា "**សង្ឃ**" គឺសំដៅលើពួក ក្រុម គណៈ ដែលជាអ្នកកម្ចាត់បង់នូវគ្រឿងសៅហ្មងពិរុទ្ធភាពទោសកំហុសទាំងបច្ចុប្បន្នទាំងអនាគត, ពាក្យថា "**សង្ឃ**" ជាបុគ្គលស្អាតស្អំបរិសុទ្ធល្អណាស់ មិនហ៊ានប្រព្រឹត្តអាក្រក់អាក្រីផ្តេសផ្តាសពាលាអាវាសែ មិនហ៊ានប្រព្រឹត្តពាធាបៀតបៀនកាប់សម្លាប់នូវបុគ្គល សត្វ មនុស្ស ឬនរណាម្នាក់ឡើយ, បើអ្នកបួសរូបណា កាប់សម្លាប់បៀតបៀននូវបុគ្គល ឬសត្វណាមួយ អ្នកបួសនោះមិនមែនជា**សង្ឃ**ឡើយ គឺជាបុគ្គលទៅវិញ ។ សូម្បីព្រះពុទ្ធជាម្ចាស់ក៏ទ្រង់ត្រាស់ក្នុង ភាសិតោវាទដែរថា "**ន ហិ បព្វជិតោ បរូបឃាតី** = អ្នកបួសដែលបៀតបៀនសត្វដទៃសម្លាប់សត្វដទៃ មិនមែនជាបព្វជិតឡើយ ពោលគឺមិនមែនជា**ព្រះសង្ឃ**ឡើយ" ។ បុគ្គលទាំងឡាយ ទោះស្ថិតនៅក្នុងតំណែងណាភេទណាក៏ដោយចុះ បើទៅសម្លាប់គេៗហៅថាឃាតកបុគ្គល

បើទៅលួចប្លន់គេៗហៅថា**ចោរ** បើទៅប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម គេហៅថា **ឧក្រិដ្ឋជន**ជាដើម, គេមិនដែលហៅឬម៉ែយកនូវឋានៈតួនាទី មុខងារ គោរម្យងារ ឬក៏ភេទមកផ្សារភ្ជាប់នឹងបុគ្គលនោះទៀតឡើយ ។ សម្ដេចគួរជ្រាប ពាក្យថា "**ព្រះសង្ឃ**" ដូចគ្នាពាក្យថា "**សភា, រដ្ឋាភិបាល**"ជាដើមអ៊ីចឹង ។

-**ព្រះសង្ឃ** គឺជាក្រុមដែលប្រព្រឹត្តល្អជានិច្ច ហើយមានឧបមាដូចរុក្ខជាតិដែរ, បើមួយដើម គេហៅថា "**ឈើ**", គេមិនហៅថា"**ព្រៃ**"ទេ, ទាល់តែឈើច្រើនដើម ទើបគេហៅថា "**ព្រៃ**"; ដូចគ្នានេះដែរ អ្នកស្ថិតនៅក្នុងសាសនា(អ្នកបួស) ប្រព្រឹត្តពិរុទ្ធភាពល្មើសវិន័យ លែងជា**ព្រះសង្ឃ**ទៀតហើយ, រឿងពិរុទ្ធភាពនោះ គឺជារឿងនៃបុគ្គលអ្នកប្រព្រឹត្តប៉ុណ្ណោះ។

-**សភា** គឺជាក្រុមអង្គការនយោបាយកំពូល មិនត្រូវមាននិន្នាការខាងក្រុមបក្សណាមួយឡើយ មានតួនាទីខាងរៀបចំតាក់តែងច្បាប់ ព្រាងពិនិត្យនិងអនុម័តច្បាប់ ហើយត្រូវទទួលខុសត្រូវ និងគោរពច្បាប់ដែលខ្លួនបានតាក់តែង និងពិនិត្យអនុម័ត, បើមានប្រធានឬក្រុមសមាជិកណាមួយ មានចេតនាចង់បង្វែងក្លែងតែងច្បាប់ ចង់អនុម័តច្បាប់ដែល

មានប្រយោជន៍ចំពោះតែបក្សពួកខ្លួន និងផ្ទុះបញ្ចាំងពីទស្សនៈនៃជនមួយក្តាប់តូច ឬប្រព្រឹត្តល្មើសច្បាប់ គឺមិនមែនជាសភាទៀតទេ ទោះបីខ្លួនស្ថិតនៅក្នុងតំណែងជាសភា និងមាន**អភ័យឯកសិទ្ធិ**ក៏ដោយចុះ, ហើយខ្ញុំជឿថា មហាជនអ្នកមានមារយាទ គង់មិនម៉ែយកបុគ្គលឬក្រុមសមាជិកណាមួយមានចេតនាបែបនោះ ឬប្រព្រឹត្តខុសបែបនោះ ថាជាសភាឡើយ ព្រោះសភា ជាក្រុមអង្គការនយោបាយច្បាប់ស្អាតស្អំបរិសុទ្ធណាស់ ហើយមានលក្ខណៈទូទៅពេញពិភពលោក ។

-**រដ្ឋាភិបាល** ជាក្រុមអង្គការនយោបាយមួយទៀត មានតួនាទីខាងស្នើច្បាប់ គោរពច្បាប់ ការពារនិងអភិវឌ្ឍប្រទេសជាតិមាតុភូមិ, បើនាយករដ្ឋមន្ត្រី មន្ត្រីជាន់ខ្ពស់ ឬមន្ត្រីក្រោមឱវាទរូបណាមួយ ប្រព្រឹត្តមិនគប្បី មានពិរុទ្ធភាពក្នុងហេតុណាមួយមានការធ្វើអំពើជួញដូរមនុស្ស និងការប្រព្រឹត្តអំពើពុករលួយជាដើម គឺមិនមែនជារបស់រដ្ឋាភិបាលទេ គឺជាកំហុសនៃបុគ្គលស្ថិតនៅក្នុងតួនាទីមុខងារតែម្តង, អត្ថន័យរបស់ពាក្យ "**រដ្ឋាភិបាល**" នៅតែពីរោះ នៅតែស្អាត

ស្អំ នៅតែគេត្រូវការប្រើ នៅតែត្រូវការគេគោរព នៅតែជាតំណែងគោរម្យ៍ងារខ្ពង់ខ្ពស់ សម្រាប់យកទៅតែងតាំងដល់បេក្ខជនដែលសុចរិតជានិច្ច,បើបុគ្គលម្នាក់កាន់តួនាទីក្នុងជួររដ្ឋាភិបាលប្រព្រឹត្តអំពើពិរុទ្ធភាព គេមិនចោទថា "**បុគ្គលនេះមានពិរុទ្ធភាព**" តែបែរជាចោទថា "**រដ្ឋាភិបាលនេះ មានពិរុទ្ធ-ភាព**", អ៊ីចឹង បេក្ខជនទាំងអស់ក្នុងលោក គ្រប់ប្រទេសដែលកាន់តំណែងជារដ្ឋាភិបាល ឬក្នុងជួររដ្ឋាភិបាល ដែលមិនបានប្រព្រឹត្តអ្វីខុសសោះនោះ ក៏ត្រូវតែមានកំហុសប្រឡាក់ឈ្មោះក្នុងអំពើពិរុទ្ធភាព គេចមិនផុតទេពីព្រោះអ្នកទាំងនោះ ក៏កាន់មុខងារជារដ្ឋាភិបាលដែរ ។

ធៀតក្នុងឱកាសនេះ សូមក្រើនរំឭកចំពោះសមណ-សង្ឃគ្រប់ព្រះអង្គក្នុងមណ្ឌលព្រះពុទ្ធសាសនាផងដែរ ត្រូវត្រិះរិះពិចារណានិងគ្រប់គ្រងមារយាទរបស់ខ្លួនឲ្យបានត្រឹមត្រូវតាមពុទ្ធោវាទ ដ្បិតពុទ្ធបរិស័ទ គេខំយកបាយទឹកនំចំណីមកប្រគេនដើម្បីយើង ដោយគិតថាយើងជាបុគ្គលប្រព្រឹត្តល្អក្នុងវិន័យព្រះសង្ឃ បើដឹងថា យើងជាបុគ្គលអា-ក្រក់ប្រព្រឹត្តពាលាអាវាសែ ម៉្ងៃះគេមិនខ្ចីយកទេយ្យទាន

អស់ទាំងនេះមកប្រគេននាំតែខាតឡើយ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ផងដែរថា **"អ្នកបួសរូបណា ដែលធាន់ចង្ហាន់ហើយមានការព្យាយាម, អ្នកបួសរូបនោះ ទើបធាន់ចង្ហាន់អ្នកនៅក្នុងដែនមិនឥតប្រយោជន៍"** ។ នេះជាឱវាទយ៉ាងពិសិដ្ឋនៃព្រះបរមគ្រូជាម្ចាស់ ទុកជាគ្រឿងដាស់សតិបព្វជិតពល់រូបឲ្យចេះអៀនចេះខ្មាស ក្នុងការប្រើប្រាស់ទេយ្យវត្ថុដែលពុទ្ធបរិសទ្យគេប្រគេនដោយសទ្ធាភាព ហើយខិតខំអប់រំខ្លួនឲ្យបានល្អ វៀរចាកអំពើគ្គាំគ្គង អំពើទុច្ចរិតអំពើឃាតកម្ម ហើយព្យាយាមបំពេញបព្វជិតកិច្ចឲ្យបានសម្រេច ទោះក្នុងកាលណាក៏ដោយចុះ ព្រោះកាលបើយើងធ្វើនូវរឿងមិនគប្បីណាមួយឲ្យឲ្យកើតឡើង វាបណ្ដាលឲ្យគេរឹល្បឿះខ្លួនគេរឹល្បឿះសាសនាអាប់ឱន និងសាយភាយភាពមិនល្អឆ្ងាយខ្លាំងណាស់ ។៕

ឧបាសកាចារ្យអគ្គសិរីវិមលញ្ញាណ **លី ប៊ុនលីន** រៀបរៀង

# ព្រះមហាធម្មាលង្ការោ ចាន់ សុជន
# ប្រធានកម្មវិធីធាជីសំឡេងព្រះធម៌
# **វត្តប្រាសាទស្រះកណ្តាល( ខ្នាស់ )**

ចានពិនិត្យ

និជ័ឃកាភាព

*ធ្វើនៅវត្តប្រាសាទស្រះកណ្តាល(ខ្នាស់)*
*ថ្ងៃ១៥កើត ខែអាសាឍ ព.ស.២៥៥៨*
*ត្រូវនឹងថ្ងៃសុក្រ ទី១១ ខែកក្កដា ឆ្នាំ២០១៤*